# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៣៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិនិងថ្នាក់សម្រាប់ចៅក្រមនិងព្រះរាជអាជ្ញា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ដើម្បីធានាបាននូវប្រសិទ្ធភាពនិងការបង្កើនផលិតភាពក្នុងប្រព័ន្ធយុត្តិធម៌ ព្រមទាំងការធានានូវសមធម៌និងសង្គតិភាពក្នុងប្រព័ន្ធបៀវត្សអនុលោមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះចៅក្រមនិងព្រះរាជអាជ្ញាដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។

## ជំពូកទី២
## ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា

**មាត្រា៤ .-**

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា រួមមាន ប្រាក់បំណាច់មុខងារចៅក្រមនិងព្រះរាជអាជ្ញា ប្រាក់បំណាច់ឈ្នួលផ្ទះ ប្រាក់បំណាច់អធិមូលជីវភាព ប្រាក់បំណាច់សម្រាប់ផ្លាស់ប្តូរទីតាំងការងារ ប្រាក់ថ្លៃព្យាបាលនៅក្នុងមន្ទីរពេទ្យ និងប្រាក់ឧបត្ថម្ភសម្រាប់ព្យាបាលជំងឺប្រចាំកាយរយៈពេលយូររបស់ចៅក្រមនិងព្រះរាជអាជ្ញា។

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានបើកផ្តល់ប្រចាំខែតាមការកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់(រៀល) |
|---|---|---|
| ១ | - ប្រធានតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | ១០ ០០០ ០០០ |
| ២ | - អនុប្រធានតុលាការកំពូល<br>- ប្រធានសភានៃតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល<br>- ប្រធានសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ៤ ៥០០ ០០០ |
| ៣ | - ចៅក្រមតុលាការកំពូល<br>- ព្រះរាជអាជ្ញាអមតុលាការកំពូល<br>- អនុប្រធានសាលាឧទ្ធរណ៍<br>- ប្រធានសភានៃសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ | ៤ ០០០ ០០០ |
| ៤ | - ចៅក្រមសាលាឧទ្ធរណ៍<br>- ប្រធានសាលាដំបូង<br>- ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍<br>- ព្រះរាជអាជ្ញាអមសាលាដំបូង<br>- ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ | ៣ ៥០០ ០០០ |
| ៥ | - អនុប្រធានសាលាដំបូង<br>- ប្រធានតុលាការជំនាញនៃសាលាដំបូង<br>- ព្រះរាជអាជ្ញារងអមសាលាដំបូង | ៣ ២០០ ០០០ |
| ៦ | - ចៅក្រមសាលាដំបូង | ៣ ០០០ ០០០ |
| ៧ | - ចៅក្រមកម្មសិក្សា<br>- ព្រះរាជអាជ្ញារងកម្មសិក្សា | ១ ៥០០ ០០០ |

**មាត្រា៥ .-**

ការបើកផ្តល់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា រួមទាំងការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ ត្រូវអនុវត្តតាមប្រព័ន្ធធនាគារ។

ចៅក្រមនិងព្រះរាជអាជ្ញាដែលទទួលមុខតំណែងលើសពីមួយ មានសិទ្ធិជ្រើសរើសប្រាក់បំណាច់តែមួយប៉ុណ្ណោះ។